អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០១១ស.-១៦អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពីការកំណត់នីតិវិធី សម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនី

## អាជ្ញាធរអគ្គិសនីកម្ពុជា និង អគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាស លេខ ០០៩៤.រ៉ថ.អវថ.ប្រក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលកំណត់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០
- បានឃើញផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានី ឆ្នាំ២០១៥-២០២០ដែលអនុម័តដោយកិច្ចពិភាក្សារវាងក្រសួងរ៉ែ និងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា, អគ្គិសនីកម្ពុជា, សាលារាជធានី/ខេត្ត និងមន្ទីររ៉ែ និងថាមពល រាជធានី/ខេត្ត នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៥
- យោងកិច្ចពិភាក្សា រវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦

## សម្រេច

### ប្រការ១

ដាក់ឲ្យអនុវត្តនីតិវិធី សម្រាប់ផ្តល់ការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនីក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ ។

### ប្រការ២

នីតិវិធីនេះ ដែលដាក់ឲ្យអនុវត្តតាមប្រការ ១ ខាងលើ មានឈ្មោះថា "នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនី" ដែលមានខ្លឹមសារទាំងស្រុង ដូចអត្ថបទភ្ជាប់មកជាមួយ ។

**ប្រការ៣**

អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា មូលនិធិអគ្គិសនីការូបនីយកម្មជនបទ របស់អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណដែលពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តការឧបត្ថម្ភធន និងការបន្ថយថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ និងប្រការ ២ ខាងលើ ឲ្យបានសុក្រឹត និងមានប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាល ។

**ប្រការ៤**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន៖</u>
-ក្រសួងរ៉ែ និងថាមពល
"ដើម្បីជូនជ្រាប"
- មូលនិធិអគ្គិសនីការូបនីយកម្មជនបទ
- គ្រប់អ្នកកាន់អាជ្ញាប័ណ្ណពាក់ព័ន្ធ
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនី
**Procedure for implementation of subsidy scheme to lower the tariff**

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈប្រកាសលេខ ០០៩៤ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ របស់ក្រសួងរ៉ែ និងថាមពល បានដាក់ចុះនូវផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ ដែលមានគោលដៅតំបូងលើតំបន់ផ្គត់ផ្គង់អគ្គិសនីទាំងឡាយ ដែលផ្តល់ប្រភពអគ្គិសនីដោយបណ្តាញជាតិ ។ បន្ថែមពីលើការបន្ថយអត្រាថ្លៃលក់អគ្គិសនីទូទៅ ប្រកាសនេះ ក៏បានកំណត់ឲ្យបន្ថយអត្រាថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់អគ្គិសនីដែលមានជីវភាពក្រីក្រួចប្រើតិច និងសម្រាប់ការប្រើប្រាស់បូមទឹកធ្វើកសិកម្មនៅពេលយប់ផងដែរ ។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ ប្រកាសនេះ បានកំណត់ឲ្យអគ្គិសនីកម្ពុជាប្រើប្រាស់ខ្ទង់ប្រាក់ចំណេញរបស់ខ្លួនមួយផ្នែក ផ្តល់ទៅឲ្យមូលនីធិអគ្គិសនីការូបនីយកម្មជនបទដើម្បីយកមកធ្វើការឧបត្ថម្ភធនដល់អ្នកកាន់អាជ្ញាបណ្ណចែកចាយអគ្គិសនីឯកជន ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិ សម្រាប់បន្ថយថ្លៃលក់អគ្គិសនីរបស់អ្នកទាំងនោះ ឲ្យទាបជាងថ្លៃពិតដែលគេត្រូវលក់ ។ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រឧបត្ថម្ភធនបន្ថយថ្លៃលក់អគ្គិសនីនេះឲ្យបានរលូន និងមានប្រសិទ្ធភាព អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា សម្រេចកំណត់អំពីនីតិវិធីសំខាន់ៗ មួយចំនួនដែលត្រូវអនុវត្តដោយអាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា (មូលនិធិអគ្គិសនីការូបនីយកម្មជនបទ) និងអ្នកកាន់អាជ្ញាបណ្ណផ្គត់ផ្គង់អគ្គិសនីឯកជន ដូចខាងក្រោម ៖

### ១.ការកំណត់ថ្លៃទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងចេញពីបណ្តាញជាតិ

ថ្លៃទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងចេញពីបណ្តាញជាតិ គឺជាមូលដ្ឋានតំបូងនៃការកំណត់ថ្លៃលក់អគ្គិសនីរាយឲ្យអ្នកប្រើប្រាស់តាមតំបន់ចែកចាយនានា ដូច្នេះការកំណត់ថ្លៃថ្លៃទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងចេញពីបណ្តាញជាតិ ក៏ជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្របន្ថយថ្លៃដែលត្រូវកំណត់អំពីនីតិវិធីដែលត្រូវអនុវត្តនៅក្នុងឯកសារនេះដែរ ។ នៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅប្រទេសកម្ពុជា ការលក់អគ្គិសនីពីអនុស្ថានីយនៃបណ្តាញជាតិ ត្រូវបានគ្រប់គ្រងដោយអគ្គិសនីកម្ពុជាទាំងស្រុង ដោយឡែកចំពោះការលក់អគ្គិសនីចេញពីបណ្តាញបញ្ជូនរង ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ដោយសារបណ្តាញបញ្ជូនរងមាន ២ ប្រភេទ គឺមួយផ្នែកត្រូវបានវិនិយោគដោយអគ្គិសនីកម្ពុជា និងមួយផ្នែកទៀត ត្រូវបានវិនិយោគដោយអ្នកវិនិយោគឯកជន ដូច្នេះការលក់អគ្គិសនីចេញពីបណ្តាញបញ្ជូនរង ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ មួយផ្នែកត្រូវបានគ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងមួយផ្នែកទៀត ត្រូវបានគ្រប់គ្រងដោយអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ។ តាមការកំណត់នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី អត្រាថ្លៃលក់អគ្គិសនីចំនួន ៣ ប្រភេទ គឺ ១.អត្រាថ្លៃលក់ចេញពីអនុស្ថានីយ ២.អត្រាថ្លៃលក់ប្រភពអគ្គិសនីឲ្យអ្នកចែកចាយ និង៣.អត្រាថ្លៃលក់សម្រាប់អ្នកប្រើប្រាស់ប្រភេទតង់ស្យុងមធ្យម MV ចេញពីបណ្តាញបញ្ជូនរងទាំងអស់ទាំងរបស់អគ្គិសនីកម្ពុជា EDC និងទាំងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ត្រូវកំណត់ឲ្យមានអត្រា និង

ទម្រង់នៃបញ្ជីថ្លៃលក់អគ្គិសនីដូចគ្នាទូទាំងប្រទេស ឲ្យតែតំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ លើកលែងតែក្នុងប្រព័ន្ធចែកចាយរាជធានីភ្នំពេញ និងកណ្តាល របស់អគ្គិសនីកម្ពុជា ដែលអាចខុសពីនេះបន្តិច ក្នុងរង្វង់ ២-៣ ឆ្នាំតំបូងនៃការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ដោយសារត្រូវបន្ថែមថ្លៃប្រើប្រាស់ផលិតកម្មអគ្គិសនីឯកជន IPP បន្ថែម ។

ចំពោះការកំណត់ថ្លៃលក់អគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងរបស់ខ្លួន នៅដំណាច់ឆ្នាំនីមួយៗ អគ្គិសនីកម្ពុជាត្រូវធ្វើការគណនាការចំណាយ-ចំណូលអាជីវកម្ម របស់ខ្លួនសម្រាប់ឆ្នាំបន្ទាប់ លើប្រព័ន្ធបណ្តាញជាតិ និងលើប្រព័ន្ធបណ្តាញបញ្ជូនរងរបស់ខ្លួន ទៅតាមអត្រាថ្លៃដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃ រួចផ្ញើរមកអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការពិនិត្យនិងកំណត់ថ្លៃ ៖ ១.អត្រាថ្លៃលក់អគ្គិសនីចេញពីអនុស្ថានីយ ២.អត្រាថ្លៃលក់ប្រភពអគ្គិសនីឲ្យអ្នកចែកចាយ និង៣.អត្រាថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទតង់ស្យុងមធ្យម MV ដែលទិញអគ្គិសនីចេញពីបណ្តាញបញ្ជូនរងសម្រាប់ឆ្នាំបន្ទាប់ ។ អត្រាថ្លៃទាំង ៣ នេះ ក៏អាចខុសពីតួលេខក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃ ប្រសិនបើស្ថានភាពជាក់ស្តែងតម្រូវ ។ បន្ទាប់ពីកំណត់អត្រាថ្លៃទាំង ៣ រួចមក អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការពិគ្រោះយោបល់ជាសាធារណៈ និងបើកសម័យប្រជុំ ដើម្បីសម្រេចលើអត្រាថ្លៃលក់អគ្គិសនីទាំង ៣ ប្រភេទខាងលើ ។ តាមគោលការណ៍នៃផែនការយុទ្ធសាស្ត្របន្តអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល អត្រាថ្លៃលក់អគ្គិសនីទាំង ៣ ប្រភេទខាងលើនេះ ក៏ត្រូវដាក់ឲ្យអនុវត្តចំពោះបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងរបស់ឯកជនផងដែរ ។ ដោយសារតែអត្រាថ្លៃអគ្គិសនីទាំង ៣ ប្រភេទខាងលើ ត្រូវបានកំណត់តាមទិន្នន័យរបស់អគ្គិសនីកម្ពុជាទាំងស្រុង ប៉ុន្តែត្រូវដាក់ឲ្យអនុវត្តចំពោះបណ្តាញបញ្ជូនរង របស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនដែរ ដូច្នេះដើម្បីឲ្យមានយុត្តិធម៌ ចំពោះអ្នកវិនិយោគឯកជន ដែលជាអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ឯកភាពអនុវត្តគោលការណ៍ និងនីតិវិធីដែលត្រូវដោះស្រាយចំពោះអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ដូចខាងក្រោម ៖

1. ចំពោះអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនណា ដែលអាចធ្វើអាជីវកម្មបញ្ជូនរងអគ្គិសនី តាមអត្រាថ្លៃកំណត់ខាងលើនេះបាន ដោយគ្មានហានិភ័យ អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជននោះ អាចបន្តអាជីវកម្មផ្ទាល់ខ្លួនបន្តទៀតជាធម្មតា ដូចពេលបច្ចុប្បន្ន ។
2. ចំពោះអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនណា ដែលពុំអាចទ្រាំទ្រធ្វើអាជីវកម្មបញ្ជូនរងជាមួយអត្រាថ្លៃកំណត់ខាងលើ អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជននោះ អាចធ្វើសំណើមកអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីពិនិត្យគណនាចំណូល-ចំណាយ និងថ្លៃលក់ឡើងវិញ រួចប្រសិនបើពិនិត្យទៅឃើញថា ការលក់តាមអត្រាថ្លៃលក់នេះ មានលទ្ធផលអាជីវកម្មមិនស្មើនឹងអត្រាចំណេញដែលត្រូវផ្តល់ឲ្យ ពេលនោះអាជ្ញាធរអគ្គិសនីកម្ពុជា អាចអនុញ្ញាតឲ្យអគ្គិសនីកម្ពុជា ធ្វើការគ្រប់គ្រងលើការលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជននោះ រួចអគ្គិសនីកម្ពុជានឹងរៀបចំថ្លៃលក់ប្រភពអគ្គិសនីរបស់ខ្លួន ទៅឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជននោះ តាមអត្រាថ្លៃពិសេសមួយ ដែលអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនអាចទទួលបាននូវចំណូលថ្លៃសេវាបណ្តាញបញ្ជូនរងរបស់ខ្លួន តាមចំនួនដែលបានគណនាឃើញថាសមរម្យនៅក្នុងឆ្នាំនោះ ។ ក្នុងករណីនេះ ការងារលក់អគ្គិសនីជូនអ្នកប្រើប្រាស់ និងអ្នកកាន់អាជ្ញាបណ្ណ គឺនៅតែធ្វើដោយអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនដដែល ប៉ុន្តែការងារនេះ ត្រូវឋិតនៅក្រោមការត្រួត

ពិនិត្យលំអិតរបស់អគ្គិសនីអគ្គិសនីកម្ពុជា ដើម្បីធានាថាការជួយរបស់អគ្គិសនីកម្ពុជា ពិតជាដើម្បីរក្សានិរន្តរភាពនៃអាជីវកម្មរបស់បណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណឯកជននេះ ឲ្យឋិតក្នុងភាពសមរម្យតាមការកំណត់ប៉ុណ្ណោះ ។

3. ក្នុងករណីដែលអគ្គិសនីកម្ពុជា ពុំទាន់មានលទ្ធភាពអភិវឌ្ឍន៍បណ្តាញបញ្ជូនតង់ស្យុងខ្ពស់ និងអនុស្ថានីយនៅខេត្តណាមួយ រួចតម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនធ្វើការបញ្ជូនប្រភពអគ្គិសនីទៅឲ្យអ្នកចែកចាយ និងអ្នកប្រើប្រាស់ MV នៅខេត្តនោះ លើសពីប្រវែងស្តង់ដាបញ្ជូនរង ២២ គីឡូវ៉ុល ធម្មតាកំណត់ដោយអគ្គិសនីកម្ពុជា ពេលនោះអគ្គិសនីកម្ពុជា អាចសម្រេចឲ្យអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជនធ្វើការបញ្ជូនរងជាបណ្តោះអាសន្នសិនទម្រាំដល់ពេលដែលអគ្គិសនីកម្ពុជាធ្វើការអភិវឌ្ឍន៍អនុស្ថានីយនៅខេត្តនោះបាន ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចមានការពិគ្រោះយោបល់ជាមួយមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា ពិនិត្យករណីបែបនេះដោយឡែក តាមតំបន់នីមួយៗ និងផ្ទៀងផ្ទាត់ចំនួនថវិកាដែលមានសម្រាប់ឧបត្ថម្ភធនបន្ថយថ្លៃ រួចអាចកំណត់ឲ្យអនុវត្តថ្លៃលក់អគ្គិសនីតាមអត្រាថ្លៃកំណត់ទូទាំងប្រទេសដូចខាងលើ ដោយឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ របស់អគ្គិសនីកម្ពុជាធ្វើការប៉ះប៉ូវការចំណាយបាត់បង់ថាមពលលើខ្សែបណ្តាញបញ្ជូនរង ដែលលើសពីអត្រាបាត់បង់ធម្មតាដោយសារប្រវែងបញ្ជូនជាក់ស្តែងឆ្ងាយជាងប្រវែងបញ្ជូនស្តង់ដារជាបណ្តោះអាសន្ន ។ ក្នុងករណីដែលថវិកាឧបត្ថម្ភធនពុំអាចមានលទ្ធភាពពេញលេញ អាជ្ញាធរអគ្គិសនីកម្ពុជាអាចពិគ្រោះយោបល់ជាមួយមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា ដើម្បីជួយឧបត្ថម្ភធន១ ផ្នែក តែលើថាមពលអគ្គិសនីប្រើប្រាស់ ដោយរក្សាទុកចំនួនដែលបាត់បង់លើខ្សែបណ្តាញបញ្ជូនរង ដែលមានចម្ងាយលើសនោះឲ្យនៅជាគម្លាតថ្លៃ រវាងតំបន់ដែលទទួលប្រភពអគ្គិសនីធម្មតា និងតំបន់ដែលទទួលប្រភពអគ្គិសនីឆ្ងាយជាងស្តង់ដារកំណត់ ។

## ២.ការកំណត់អត្រាថ្លៃលក់អគ្គិសនី នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា

ការផ្គត់ផ្គង់អគ្គិសនីរាយឲ្យអ្នកប្រើប្រាស់អគ្គិសនី ត្រូវបានបែកចែកជាតំបន់ចែកចាយ ទៅតាមតំបន់វិនិយោគរបស់អ្នកកាន់អាជ្ញាបណ្ណនីមួយៗ។ តំបន់ចែកចាយទាំងនេះ ត្រូវបានកំណត់ព្រំដែនដោយអាជ្ញាបណ្ណចែកចាយដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជាឲ្យអ្នកកាន់អាជ្ញាបណ្ណនីមួយៗ ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ នៅពេលបច្ចុប្បន្ននេះ តំបន់ចែកចាយអគ្គិសនីទាំងអស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានមួយផ្នែក គឺត្រូវបានវិនិយោគនិងគ្រប់គ្រងការផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា និងមួយផ្នែកទៀតត្រូវបានវិនិយោគនិងគ្រប់គ្រងការផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាបណ្ណឯកជន ។ ក្នុងការកំណត់អត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ជាគោលការណ៍ ត្រូវបានកំណត់ឲ្យដាក់អាជីវកម្មចំណេញខាតនៃតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំងអស់រួមគ្នា រួចកំណត់បញ្ជីថ្លៃលក់ឯកភាពមួយ សម្រាប់តំបន់ទាំងអស់លើកលែងតែតំបន់មួយចំនួនតូចដែលមានថ្លៃទាបយូរមកហើយ រួចមិនអាចកែតម្រូវបាន ទោះជាអាជីវកម្មមានការខាតបង់ក៏ដោយ ដោយសារស្ថានភាពនយោបាយបច្ចុប្បន្ន ។ ចំពោះការកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំងអស់នេះ នៅដំណាច់ឆ្នាំនីមួយៗ អគ្គិសនីកម្ពុជា ត្រូវធ្វើការគណនាការចំណាយ-ចំណូលអាជីវកម្ម ទី១.លើការចែកចាយអគ្គិសនីនៅតំបន់ចែកចាយនីមួយៗសម្រាប់ឆ្នាំបន្ទាប់ ទៅតាម

អត្រាថ្លៃគ្រប់ប្រភេទអតិថិជន ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃរួចហើយ និងទី២.លើការដាក់រួមបញ្ចូលគ្នា នៃតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំងអស់នេះ ។ បន្ទាប់ពីគណនារួច អគ្គិសនីកម្ពុជាត្រូវផ្ញើការគណនានេះ មកអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំងអស់នោះ ។ បញ្ជីថ្លៃលក់នេះ អាចខុសពីចំនួនដែលកំណត់នៅក្នុងផែនការ ប្រសិនបើស្ថានភាពជាក់ស្តែងតម្រូវ ។ ការកំណត់អត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំងអស់នេះ មិនមានការឧបត្ថម្ភធនទេ ប៉ុន្តែត្រូវមានចំណេញតាមចំនួនមួយដែលអាចកាត់កងប្រាក់ចំណេញនេះ មួយផ្នែកយកទៅធ្វើជាថវិកាឧបត្ថម្ភធនសម្រាប់បន្ថយអត្រា និងគម្លាតថ្លៃនៅតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណចែកចាយឯកជន ។

## ៣.ការកំណត់តំបន់ចែកចាយអគ្គិសនីដែលត្រូវទទួលបានការឧបត្ថម្ភធនដើម្បីបន្ថយថ្លៃ

តំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណចែកចាយឯកជន មានច្រើនប្រភេទ ទៅតាមការយកប្រភពអគ្គិសនីមកធ្វើការផ្គត់ផ្គង់ ។ តាមការសិក្សា និងគណនាកន្លងមក លទ្ធភាពនៃការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី គឺអាចធ្វើបានតែក្នុងតំបន់ចែកចាយណាដែលយកប្រភពអគ្គិសនីរបស់បណ្តាញជាតិ មកផ្គត់ផ្គង់ប៉ុណ្ណោះ ។ ដូច្នេះដើម្បីឲ្យមានភាពច្បាស់លាស់នៅក្នុងការអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណចែកចាយឯកជន យើងកំណត់តំបន់ចែកចាយអគ្គិសនី របស់អ្នកកាន់អាជ្ញាបណ្ណចែកចាយឯកជន ដែលអាចទទួលបានការឧបត្ថម្ភធន ដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីដូចខាងក្រោម ៖

(១). តំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ដែលបានភ្ជាប់ និងទិញប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ឬ/និង ទិញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឬ/និង ទិញពីបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ

(2) តំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ដែលបានទិញអគ្គិសនីមួយផ្នែកពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ (ទិញពីអនុស្ថានីយបណ្តាញជាតិ ឬទិញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឬទិញពីបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ) និងមួយផ្នែកទៀតពីប្រភពផ្សេងៗ ដូចជាពីប្រភពនាំចូលពីប្រទេសជិតខាង ពីអ្នកកាន់អាជ្ញាបណ្ណផលិតណាមួយ ឬពីផលិតកម្មផ្ទាល់របស់ខ្លួន ។ តំបន់ដែលរៀបរាប់ខាងលើនេះ អាចទទួលការឧបត្ថម្ភធនពីមូលនិធិអគ្គិសនីការូបនីយកម្ម ដើម្បីបន្ថយអត្រាថ្លៃអគ្គិសនីបានលុះត្រាតែ ៖ ទី១.ការទិញប្រភពអគ្គិសនីពីប្រភពផ្សេងៗ ក្រៅពីប្រភពបណ្តាញជាតិ ទទួលបានការអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា និងទី២.ថ្លៃប្រភពអគ្គិសនីដែលទិញពីប្រភពផ្សេងៗ ទាំងនោះមានអត្រាប្រហាក់ប្រហែលនឹងថ្លៃដែលទិញពីបណ្តាញជាតិដែរ ។ ចំពោះករណីដូចខាងលើនេះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវពិនិត្យ និងសម្រេចដោយឡែកតាមករណីនីមួយៗ ដោយធ្វើការសិក្សា និងពិគ្រោះយោបល់ជាមួយមូលនិធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជាជាមុន ដើម្បីការពារមិនឲ្យចំនួនឧបត្ថម្ភធនលើសពីចំនួនថវិកាដែលមាន និងធ្វើយ៉ាងណាឲ្យការបន្ថយថ្លៃមានប្រសិទ្ធភាពខ្ពស់ ។

(3) តំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ដែលបានបន្តជាបណ្តោះអាសន្នពីអ្នកកាន់អាជ្ញាបណ្ណចែកចាយមួយទៀត ដែលយកប្រភពពីបណ្តាញជាតិ និង/ឬបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង/ឬបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ដែលខ្សែបណ្តាញបញ្ជូនរងមិនទាន់ពង្រីកទៅដល់ តែអគ្គិសនីកម្ពុជាមានផែនការពង្រីកទៅដល់ទីនោះ និងបានឯកភាពជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការជួយចេញថ្លៃសេវាបញ្ជូនបន្តជាបណ្តោះអាសន្ន ឲ្យអ្នកកាន់អាជ្ញាបណ្ណចែកចាយដែលបញ្ជូនបន្តនេះ។

ចំពោះតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណចែកចាយឯកជនណា ដែលមិនទាន់យកប្រភពអគ្គិសនីរបស់បណ្តាញជាតិមកផ្គត់ផ្គង់ ដោយនៅប្រើប្រភពអគ្គិសនីពីផលិតកម្មផ្ទាល់ខ្លួន ឬទិញប្រភពអគ្គិសនីពីអ្នកផលិតទោលណាមួយ ឬប្រើប្រភពអគ្គិសនីពីការនាំចូលពីប្រទេសជិតខាង តំបន់ចែកចាយទាំងនោះ មិនទាន់អាចទទួលបានការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃនៅក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃខាងលើឡើយ ។ ដើម្បីអាចបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅតំបន់ទាំងនេះបាន គេត្រូវពង្រីកការផ្គត់ប្រភពអគ្គិសនីចេញពីប្រព័ន្ធបណ្តាញជាតិ ឲ្យទៅគ្របដណ្តប់តំបន់ទាំងនោះសិន ទើបអាចអនុវត្តការឧបត្ថម្ភធនដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីបាន ។

តំបន់ផ្គត់ផ្គង់អគ្គិសនីដែលជាតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម ឬតំបន់ផ្សារទំនើប ទោះជាតំបន់នោះយកប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ឬពីបណ្តាញបញ្ជូនរង ឬបណ្តាញតង់ស្យុងមធ្យមផម្មតារបស់អគ្គិសនីកម្ពុជា ឬពីបណ្តាញបញ្ជូនរងរបស់អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ឬពីប្រភពអគ្គិសនីពីរោងចក្រអគ្គិសនីផ្ទាល់ ឬពីប្រភពនាំចូលពីប្រទេសជិតខាង ឬក៏ប្រើប្រភពអគ្គិសនីច្រើនបញ្ចូលគ្នាក៏ដោយ បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ឧស្សាហកម្ម ឬតំបន់ផ្សារទំនើប ត្រូវកំណត់ជាក់ស្តែងទៅតាមគោលការណ៍អាជីវកម្ម ដែលច្បាប់ស្តីពីអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាបានកំណត់ ដោយពុំមានការឧបត្ថម្ភធនឡើយ ។ ដូច្នេះអត្រាថ្លៃអគ្គិសនីនៅតំបន់ឧស្សាហកម្ម ឬតំបន់ផ្សារទំនើបនីមួយៗ មិនដូចគ្នាទេ រួចអាចខ្ពស់ជាង ឬទាបជាង "អត្រាថ្លៃឧបត្ថម្ភធន" ដែលបានកំណត់តាមផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល ។

## ៤.ការគណនា "អត្រាថ្លៃពិត" និងការកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" នៅតំបន់ចែកចាយដែលគ្រប់គ្រងដោយអ្នកកាន់អាជ្ញាបណ្ណឯកជន

"អត្រាថ្លៃពិត" គឺជាអត្រាថ្លៃដែលបានមកពីការគណនា ដោយឈរលើមូលដ្ឋាននៃការចំណាយសមរម្យស្របទៅតាមគោលការណ៍ដែលកំណត់ដោយច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិ ព្រមទាំងឈរលើមូលដ្ឋាននៃការអនុញ្ញាតឲ្យមានអត្រាចំណេញប្រហាក់ប្រហែល ១០ % លើតម្លៃអចលនទ្រព្យពិត នៅក្នុងឆ្នាំដែលគណនា ។

"អត្រាថ្លៃឧបត្ថម្ភធន" គឺជាអត្រាថ្លៃដែលបានមកពីការកំណត់ឲ្យទាបជាង "អត្រាថ្លៃពិត" ដោយប្រើថវិកាឧបត្ថម្ភធនប៉ះប៉ូវឲ្យអ្នកធ្វើអាជីវកម្ម ដើម្បីឲ្យគេទទួលបានចំណូលដូចការលក់តាម "អត្រាថ្លៃពិត" ដែរ ។ ដោយសារតែការកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" ត្រូវកំណត់ទូទាំងប្រទេសឲ្យមានអត្រាឯកភាពគ្នា និងត្រូវឲ្យអត្រានេះឋិតក្នុងក្របខណ្ឌនៃចំនួនថវិកាឧបត្ថម្ភធន ដែលមាននៅឆ្នាំនោះអាចអនុវត្តបាន ដូច្នេះចៀសមិនផុតពី

ត្រូវកំណត់អត្រានេះ នៅក្នុងកម្រិតមួយដែលទាបជាង "អត្រាថ្លៃពិត" របស់អ្នកកាន់អាជ្ញាបណ្ណចែកចាយមួយចំនួនធំ រួចអាចនៅសល់អ្នកកាន់អាជ្ញាបណ្ណចែកចាយតិចតួចដែល "អត្រាថ្លៃឧបត្ថម្ភធន" ដែលកំណត់នេះ អាចខ្ពស់ជាង "អត្រាថ្លៃពិត" បន្តិចបន្តួច ។

តាមគោលការណ៍ តំបន់ចែកចាយអគ្គិសនីទាំងឡាយណា ដែលត្រូវបានកំណត់ថាអាចទទួលថវិកាឧបត្ថម្ភធនដើម្បីបន្ថយថ្លៃឲ្យអ្នកប្រើប្រាស់ អ្នកកាន់អាជ្ញាបណ្ណនៃតំបន់ចែកចាយនោះ ត្រូវមានកាតព្វកិច្ចបន្ថយអត្រាថ្លៃទូទៅផង និងត្រូវផ្ដល់អត្រាថ្លៃអនុគ្រោះឲ្យទៅប្រភេទអ្នកប្រើប្រាស់អគ្គិសនីរបស់ខ្លួនផង ស្របទៅតាមការកំណត់ក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល ។ ដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅក្នុងតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ដែលមានសិទ្ធទទួលបានថវិកាឧបត្ថម្ភធនឲ្យបានរលូន ដោយរក្សាបាននូវស្ថិរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីនៅតំបន់នោះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការគណនាចំណាយ-ចំណូលអាជីវកម្ម របស់អ្នកកាន់អាជ្ញាបណ្ណនោះ តាមគោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនីដែលកំណត់ដោយច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ "អត្រាថ្លៃពិត" ដែលអ្នកកាន់អាជ្ញាបណ្ណត្រូវលក់ឲ្យអ្នកប្រើប្រាស់ប្រភេទផ្សេងៗ ដែលទិញអគ្គិសនីពីខ្លួន ប្រសិនបើគ្មានថវិកាឧបត្ថម្ភធន ។ លទ្ធផលនៃការគណនាត្រូវធ្វើការពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាបណ្ណ និងមូលនីធិអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជា ។ តាមគោលការណ៍ដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ អត្រាថ្លៃអគ្គិសនីដែលលក់តាមខ្សែបណ្ដាញតង់ស្យុងមធ្យម របស់តំបន់ចែកចាយត្រូវអនុវត្តតាមអត្រាថ្លៃ MV ដែលបានកំណត់នៅចំណុចទី ១ ខាងលើ ដើម្បីឲ្យមានការឯកភាពទូទាំងប្រទេស រួចអត្រាថ្លៃអគ្គិសនីដែលលក់ឲ្យអ្នកប្រើប្រាស់ធុនមធ្យមដែលទិញពី LV ក្រោមត្រង់ស្វូចែកចាយផ្ទាល់ ក៏ត្រូវគិតតាមមូលដ្ឋាននៃអត្រាថ្លៃ MV ដែលបានកំណត់នៅចំណុចទី ១ ខាងលើដែរ ដោយគ្រាន់តែបន្ថែមការបាត់បង់ថាមពលលើត្រង់ស្វូ និងបន្ថែមថ្លៃវិនិយោគលើប្រព័ន្ធត្រង់ស្វូ ។ ដូច្នេះអ្វីដែលត្រូវគណនា និងកំណត់ គឺអត្រាថ្លៃលក់រាយប៉ុណ្ណោះ ។

ពិតមែនតែផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាល បានកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" ជាមូលដ្ឋានតាមបណ្ដាឆ្នាំនីមួយៗ រួចហើយ ប៉ុន្តែ "អត្រាថ្លៃឧបត្ថម្ភធន"ទាំងនោះ គឺគ្រាន់តែជាគោលដៅនៃផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីដែលបានសិក្សាប៉ុណ្ណោះ ដូច្នេះដើម្បីឲ្យការអនុវត្តការផ្ដល់ឧបត្ថម្ភធន និងការបន្ថយថ្លៃអាចដំណើរការទៅបានដោយគ្មានហានិភ័យ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការគណនា និងសិក្សាកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" តាមឆ្នាំឡើងវិញ ។ ដើម្បីកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" នេះ តំបូងអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវធ្វើការកំណត់ចំនួនទុនសរុបដែលអគ្គិសនីកម្ពុជាមាន សម្រាប់ឧបត្ថម្ភធននៅក្នុងឆ្នាំដែលត្រូវអនុវត្តថ្លៃ ។ បន្ទាប់មក ក្នុងក្របខណ្ឌនៃថវិកាដែលមានសម្រាប់ឧបត្ថម្ភធននេះ និងយោងតាមផែនការយុទ្ធសាស្ត្របន្ថយអត្រានិងគម្លាតថ្លៃនិងថ្លៃអនុគ្រោះថ្មីទៀត ដែលប្រមុខរាជរដ្ឋាភិបាលបានសម្រេច អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការគណនា ដើម្បីកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" ទាំងអត្រាថ្លៃលក់ទូទៅ ទាំងអត្រាថ្លៃលក់សម្រាប់អ្នកក្រីក្រប្រើមិនលើស ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ និងទាំងអត្រាថ្លៃលក់សម្រាប់អ្នកមិនលើស ៥០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ដែលគ្រប់តំបន់ចែកចាយអគ្គិសនីដែលទទួលការឧបត្ថម្ភធនបន្ថយថ្លៃនៅក្នុងឆ្នាំនោះ ត្រូវលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់តាម "អត្រាថ្លៃឧបត្ថម្ភធន" ដែលបានកំណត់នេះ ។ អ្នកកាន់អាជ្ញាបណ្ណនឹងទទួលបាននូវការប៉ះប៉ូវបង្គ្រប់ថ្លៃ ពីមូលនីធិអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជា ចំពោះការលក់អគ្គិសនីតាម "**អត្រាថ្លៃឧបត្ថម្ភធន**" ដែលបានកំណត់ខាងលើនេះ ។ ដូច្នេះការកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" ត្រូវធ្វើយ៉ាង

ណាឲ្យចំនួនសរុបនៃថវិកាត្រូវឧបត្ថម្ភធន ឋិតនៅក្នុងក្របខណ្ឌនៃទុនដែលមានសម្រាប់ការឧបត្ថម្ភធន។ លទ្ធផលនៃការគណនា និងការកំណត់ "អត្រាថ្លៃឧបត្ថម្ភធន" ត្រូវធ្វើការពិគ្រោះយោបល់ជាមួយមូលនីធិអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជា ដែលជាអ្នកទទួលបន្ទុកឧបត្ថម្ភធន ។

## ៤.ការដាក់ពាក្យស្នើសុំថវិកាឧបត្ថម្ភធនពីមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ

អ្នកកាន់អាជ្ញាបណ្ណចែកចាយអគ្គិសនី ដែលត្រូវបានអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ឲ្យអនុវត្តអត្រាថ្លៃឧបត្ថម្ភធន អាចមានសិទ្ធទទួលបានការឧបត្ថម្ភធនពីមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ របស់អគ្គិសនីកម្ពុជាមកប៉ះប៉ូវបង្គ្រប់ "អត្រាថ្លៃពិត" វិញ ។ ដើម្បីបានថវិកាឧបត្ថម្ភធនមកប៉ះប៉ូវថ្លៃរបស់ខ្លួនវិញ អ្នកកាន់អាជ្ញាបណ្ណចែកចាយអគ្គិសនីនោះ ត្រូវដាក់ពាក្យសុំថវិកាឧបត្ថម្ភធនទៅមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ នៅដំណាច់ខែនីមួយៗ ដោយភ្ជាប់ជាមួយនូវព័ត៌មានដូចខាងក្រោម ៖ (១) ការទិញ និងផលិតអគ្គិសនីដោយមានច្បាប់ចម្លងនៃឯកសារដែលបង្ហាញអំពីការងារទាំងនេះ (២) ចំនួនលក់សរុបឲ្យអ្នកប្រើប្រាស់ប្រភេទខុសៗ គ្នា និង (៣) ការលក់អគ្គិសនីឲ្យប្រភេទអ្នកប្រើប្រាស់តាមអត្រាថ្លៃឧបត្ថម្ភធន និងតារាងគណនាចំនួនថវិកាដែលមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ ត្រូវឧបត្ថម្ភធន តាមគំរូដែលបានភ្ជាប់មកជាមួយនៅឧបសម្ព័ន្ធ ១, ២ និង ៣ ។ អ្នកកាន់អាជ្ញាបណ្ណត្រូវផ្តល់នូវព័ត៌មានខាងលើនេះ ឲ្យបានគ្រប់គ្រាន់ និងឲ្យបានត្រឹមត្រូវ ដើម្បីឲ្យថវិកាឧបត្ថម្ភធនអាចផ្ទេរទៅគណនីរបស់អ្នកកាន់អាជ្ញាបណ្ណទាន់ពេល ។ ឯកសារស្នើសុំថវិកាឧបត្ថម្ភធននេះ ត្រូវធ្វើជា ២ ច្បាប់ រួចយកទៅមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ នៅពេលពិនិត្យថាច្បាប់ទាំង ២ នេះ ដូចគ្នាហើយ មូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ ត្រូវវាយត្រាទទួលលើឯកសារទាំង ២ ច្បាប់ ដោយមានចុះថ្ងៃ ខែ ឆ្នាំ ទទួល រួចបង្វិល ១ ច្បាប់ឲ្យទៅអ្នកកាន់អាជ្ញាបណ្ណវិញ ដើម្បីទុកជាឯកសារ ។ ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណមានប្រព័ន្ធ email អ្នកកាន់អាជ្ញាបណ្ណអាចចុះអនុស្សារណៈជាមួយមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ អំពីនីតិវិធីផ្ញើរតាម email ដើម្បីសម្រួលការផ្ញើរឲ្យបានរហ័ស និងចំណាយអស់តិច។ ក្នុងពាក្យស្នើសុំថវិកាឧបត្ថម្ភធននេះ អ្នកកាន់អាជ្ញាបណ្ណក៏ត្រូវផ្តល់នូវព័ត៌មានលំអិតអំពីធនាគាររបស់ខ្លួនដែលរួមមានឈ្មោះធនាគារទីតាំងសាខា ឈ្មោះម្ចាស់គណនី និងលេខគណនី ដែលអាចឲ្យមូលនីធិភាវូបនីយកម្មអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជា អាចធ្វើការផ្ទេរចំនួនថវិកាឧបត្ថម្ភធនទៅគណនីធនាគាររបស់អ្នកកាន់អាជ្ញាបណ្ណ ។

អ្នកកាន់អាជ្ញាបណ្ណត្រូវទិញអគ្គិសនីពីប្រភពណា ដែលទទួលបានការអនុញ្ញាតនៅក្នុងឯកសារអាជ្ញាបណ្ណរបស់ខ្លួន ។ ការទិញ ឬផលិតអគ្គិសនីខុសពីការកំណត់នៅក្នុងឯកសារអាជ្ញាបណ្ណ អ្នកកាន់អាជ្ញាបណ្ណនោះនឹងមិនត្រូវទទួលបានការឧបត្ថមធនពីមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជាឡើយ ។

## ៥.ការទូទាត់ថវិកាឧបត្ថម្ភធនរបស់មូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ

បន្ទាប់ពីទទួលបានពាក្យស្នើសុំថវិកាឧបត្ថម្ភធនបន្ថយថ្លៃអគ្គិសនី ដោយភ្ជាប់មកជាមួយនូវទិន្នន័យ និងព័ត៌មាន ដែលមូលនីធិអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជាត្រូវការពីអ្នកកាន់អាជ្ញាបណ្ណ ដើម្បីដំណើរការផ្តល់ការឧបត្ថម្ភធន មូលនីធិអគ្គិសនីជនបទរបស់អគ្គិសនីកម្ពុជាត្រូវពិនិត្យមើលថា តើព័ត៌មានដែលផ្តល់ទាំងនេះ គ្រប់គ្រាន់តាមការតម្រូវទេ និងពិនិត្យមើលជារួមថា តើការគណនាចំនួនថវិកាឧបត្ថម្ភធនត្រឹមត្រូវទេ? ។ ប្រសិនបើព័ត៌មានផ្តល់ឲ្យមិនទាន់គ្រប់គ្រាន់ ឬក៏ពិនិត្យឃើញមានកំហុសក្នុងការគណនា មូលនីធិអគ្គិសនីភាវូបនីយកម្មជនបទត្រូវផ្តល់ព័ត៌មានអំពីបញ្ហាទាំងនេះ ដល់អ្នកកាន់អាជ្ញាបណ្ណវិញ ក្នុងរយៈពេលមិនលើសពី ៧ ថ្ងៃ បន្ទាប់ពី

ថ្ងៃទទួលពត៌មានទាំងនេះ ។ នៅពេលទទួលបានពត៌មានគ្រប់គ្រាន់ទាក់ទងនឹងការស្នើសុំថវិកាឧបត្ថម្ភធននេះ មូលនីធិអគ្គិសនីការូបនីយកម្មជនបទ ត្រូវផ្ទេរចំនួនថវិកាឧបត្ថម្ភធននេះ ទៅគណនីធនាគាររបស់អ្នកកាន់អាជ្ញាបណ្ណភ្លាម ក្នុងរយៈពេលមិនលើសពី ៧ ថ្ងៃបន្ទាប់ពីទទួលពត៌មាន ទោះជាមិនទាន់បានត្រួតពិនិត្យលំអិតឲ្យបានត្រឹមត្រូវលើទិន្នន័យ និងពត៌មានទាំងនេះក៏ដោយ ។ ជាគោលការថ្លៃសេវាផ្ទេរប្រាក់ពីគណនីយរបស់មូលនីធិអគ្គិសនីការូបនីយកម្មជនបទ ទៅគណនីយរបស់អ្នកកាន់អាជ្ញាបណ្ណ ត្រូវជាបន្ទុករបស់មូលនីធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា ពីព្រោះថ្លៃឧបត្ថម្ភធនដែលបានគណនា មិនបានបញ្ចូលថ្លៃសេវាផ្ទេរប្រាក់ឡើយ ។ ដើម្បីជួយសម្រួលបន្ថយថ្លៃសេវាផ្ទេរប្រាក់ពីគណនីយរបស់មូលនីធិអគ្គិសនីការូបនីយកម្មជនបទ ទៅគណនីយរបស់អ្នកកាន់អាជ្ញាបណ្ណ នីតិវិធីនេះតម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណបើកគណនីយរបស់គេ នៅធនាគារដែលមូលនីធិអគ្គិសនីការូបនីយកម្មជនបទ កំណត់ ។

## ៦.ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការឧបត្ថម្ភធន ដោយមូលនីធិអគ្គិសនីការូបនីយកម្មជនបទ

មូលនីធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា មានសិទ្ធធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការស្នើសុំថវិកាឧបត្ថម្ភធនរបស់អ្នកកាន់អាជ្ញាបណ្ណ ក្នុងរយៈពេល ១២ ខែ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដែលមានពត៌មានគ្រប់គ្រាន់ ។ ដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ភាពត្រឹមនៃការឧបត្ថម្ភធននេះ តំណាងរបស់មូលនីធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា អាចចុះទៅដល់ការិយាល័យរបស់អ្នកកាន់អាជ្ញាបណ្ណរួចធ្វើការត្រួតពិនិត្យកំណត់ត្រាផ្សេងៗ និងទិន្នន័យលំអិតផ្សេងៗ ដូចជាអចលនទ្រព្យលំអិត និងការចំណាយទាំងឡាយដែលអ្នកកាន់អាជ្ញាបណ្ណប្រើប្រាស់ ដើម្បីគណនាចំនួនដែលត្រូវឧបត្ថម្ភធន ។ អ្នកកាន់អាជ្ញាបណ្ណត្រូវតែសហការណ៍ជាមួយមូលនីធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា ក្នុងការផ្តល់កំណត់ត្រាផ្សេងៗ ទិន្នន័យផ្សេងៗ ព្រមទាំងជួយក្នុងការពិនិត្យផ្ទៀងផ្ទាត់ ។ ប្រសិនបើពិនិត្យទៅឃើញថា មានលំអៀងនៅក្នុងការស្នើសុំថវិកាឧបត្ថម្ភធនដែលធ្វើដោយអ្នកកាន់អាជ្ញាបណ្ណ រួចលំអៀងនេះ ត្រូវបានឯកភាពដោយភាគីទាំង ២ ពេលនោះ មូលនីធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា នឹងកាត់កង ឬបន្ថែមនៅក្នុងការទូទាត់ថវិកាឧបត្ថម្ភធននៅពេលក្រោយបន្ទាប់ទៀត ។ ការរកឃើញមានលំអៀងនេះ មូលនីធិអគ្គិសនីការូបនីយកម្មជនបទ ត្រូវរាយការណ៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាដឹង ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាអាចមានចំណាត់ការ ដើម្បីកែតម្រូវបញ្ហាលំអៀងនេះ រួមមានការគណនាបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ និងការដាក់ពិន័យចំពោះអ្នកកាន់អាជ្ញាបណ្ណដែលបានផ្តល់ពត៌មានមិនត្រឹមត្រូវ ដែលធ្វើឲ្យកើតមានលំអៀងនេះ ។ អ្នកកាន់អាជ្ញាបណ្ណត្រូវតែរក្សាទុកនូវកំណត់ត្រានានា អំពីលេខអំណាននាឡិកាស្ទង់ ចំនួនប្រើប្រាស់ប្រចាំខែ និងអត្រាថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់នីមួយៗ ការចំណាយនានា និងបញ្ជីអចលនទ្រព្យ ។ អ្នកកាន់អាជ្ញាបណ្ណត្រូវរក្សាកំណត់ត្រាទាំងនេះក្នុងរយៈពេលយ៉ាងតិច ២ ឆ្នាំ ដើម្បីផ្តល់លទ្ធភាពឲ្យមូលនីធិអគ្គិសនីការូបនីយកម្មជនបទ អាចធ្វើការពិនិត្យផ្ទៀងផ្ទាត់ក្នុងរយៈពេល ១ ឆ្នាំ និងផ្តល់លទ្ធភាពឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានលទ្ធភាពអាចមានចំណាត់ការផ្សេងៗ ក្នុងករណីមានលំអៀងកើតឡើង ។ ការខ្វះ ឬមិនបានប្រគល់នូវកំណត់ត្រានានា អំពីលេខអំណាននាឡិកាស្ទង់ ចំនួនប្រើប្រាស់ប្រចាំខែ និងអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកប្រើប្រាស់នីមួយៗ ការចំណាយ

នានា និងបញ្ជីអចលនទ្រព្យ ចំពោះអ្នកត្រួតពិនិត្យ ត្រូវចាត់ទុកថាបានរំលោភលើនីតិវិធីនេះ ដែលត្រូវទទួលការពិន័យ ។

## ៧.នីតិវិធីសម្រាប់អនុវត្ត ចំពោះតំបន់ប្រើប្រាស់ប្រព័ន្ធនាឡិកាស្ទង់ Prepaid

នៅក្នុងចំណោមតំបន់ចែកចាយអគ្គិសនីទាំងអស់នៅកម្ពុជា មានតំបន់មួយចំនួនតូច បានប្រើប្រាស់ប្រព័ន្ធនាឡិកាស្ទង់ Prepaid ។ ក្នុងប្រព័ន្ធនេះ ពុំមានការកំណត់ឲ្យអតិថិជនបង់ប្រាក់កក់ទេ ដើម្បីប្រើប្រាស់អគ្គិសនីអតិថិជន ត្រូវទិញបណ្ណ ឬកាតដែលមានផ្ទុកទិន្នន័យចំនួនអគ្គិសនីនៅក្នុងនោះ យកទៅដាក់បញ្ចូលក្នុងនាឡិកាស្ទង់របស់ខ្លួន ។ ក្នុងករណីប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីអនុវត្តយន្តការឧបត្ថម្ភធនបន្ថយថ្លៃអគ្គិសនី និងអនុគ្រោះថ្លៃអគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា (មូលនិធិអគ្គិសនីការូបនីយកម្មជនបទ) ឯកភាពកំណត់នីតិវិធីអនុវត្ត ដូចខាងក្រោម ៖

1. ចំពោះការលក់ប័ណ្ណ ឬកាតដែលមានផ្ទុកទិន្នន័យចំនួនអគ្គិសនី ឲ្យប្រជាពលរដ្ឋ ដើម្បីយកទៅបញ្ចូលប្រើប្រាស់ សម្រាប់អតិថិជនដែលទិញពីខ្សែបណ្ដាញសាធារណៈតង់ស្យុងទាបទាំងអស់ អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវលក់ប័ណ្ណ ឬកាតនេះ តាមអត្រាថ្លៃ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ទាំងអស់ ។ បរិមាណគីឡូវ៉ាត់ម៉ោងទាំងអស់ ដែលប្រជាពលរដ្ឋបានទិញក្នុងខែនីមួយៗ តាមតម្លៃ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដែលបានកំណត់ខាងលើ ត្រូវទទួលបានការឧបត្ថម្ភធនពីមូលនីធិអគ្គិសនីការូបនីយកម្មជនបទ ស្របតាមការកំណត់ "អត្រាថ្លៃពិត" នៃអគ្គិសនីរបស់តំបន់ផ្គត់ផ្គង់នោះ ។
2. ចំពោះការអនុវត្តន៍ថ្លៃអគ្គិសនីអនុគ្រោះ សម្រាប់លំនៅដ្ឋាន ប្រើប្រាស់មិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ អ្នកផ្គត់ផ្គង់អគ្គិសនីត្រូវចុះស្រង់លេខអំណាននាឡិកាស្ទង់ប្រចាំខែ របស់ទីតាំងនីមួយៗ ដូចជាក្នុងករណីនាឡិកាស្ទង់ទូទៅដែរ ។ ប្រសិនបើការចុះស្រង់លេខអំណាននេះបង្ហាញថា អ្នកប្រើប្រាស់ណាដែលប្រើមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ អ្នកប្រើប្រាស់នោះ ត្រូវទទួលបានការអនុគ្រោះអត្រាថ្លៃលក់ត្រឹមតែ ៤៨០ រៀល ប៉ុណ្ណោះ ដូច្នេះអ្នកផ្គត់ផ្គង់នៅដំណាច់ខែនីមួយៗ ត្រូវបង្វែរចំនួនថវិកាដែលត្រូវអនុគ្រោះឲ្យអ្នកប្រើប្រាស់ ដែលប្រើមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ នោះឲ្យទៅជាចំនួន គីឡូវ៉ាត់ម៉ោង ដែលត្រូវបញ្ចូលទៅក្នុងប័ណ្ណ ឬកាតថ្មីរបស់អ្នកប្រើប្រាស់ សម្រាប់ការប្រើប្រាស់បន្តទៀត ។
3. អ្នកផ្គត់ផ្គង់អគ្គិសនី ត្រូវធ្វើរបាយការណ៍អំពីបរិមាណអគ្គិសនីដែលអ្នកប្រើប្រាស់បានទិញ តាមអត្រាថ្លៃ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ទាំងអស់, ចំនួនអ្នកប្រើប្រាស់ទាំងអស់ដែលប្រើអគ្គិសនីពីខ្សែបណ្ដាញសាធារណៈតង់ស្យុងទាប ក្នុងខែនោះ និងចំនួនអគ្គិសនីដែលអ្នកប្រើប្រាស់បានទិញប័ណ្ណ ឬកាតតាមអត្រាថ្លៃ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ក្នុងខែនោះ, ចំនួនអ្នកប្រើប្រាស់ដែលប្រើមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ក្នុងខែនោះ និងចំនួនអគ្គិសនីដែលអ្នកប្រើមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ក្នុងខែនោះ បានប្រើជាក់ស្ដែង ដើម្បីធ្វើរបាយការណ៍សុំការឧបត្ថម្ភធនពីមូលនីធិអគ្គិសនីការូបនីយកម្មជនបទ ដើម្បីប៉ះប៉ូវថវិការបស់ខ្លួនវិញ ។

*******

# តារាងឧបសម្ព័ន្ធទី១

## តារាងទិញ និងផលិតថាមពលអគ្គិសនី

## Table for Purchase and generation of electricity

ឈ្មោះអ្នកកាន់អាជ្ញាបណ្ណ៖

Name of the Licensee:

លេខអាជ្ញាបណ្ណ៖

License Number

ទិន្នន័យសម្រាប់ខែ៖

Data for the month of:

| | | | |
|---|---|---|---|
| 1 | Purchase of Electricity បរិមាណថាមពលទិញ | Purchased ចំនួនទិញ ( kWh ) | Rate of purchase អត្រាថ្លៃ |
| | Purchased From ទិញពី | | |
| | a. | | |
| | b. | | |
| | c. | | |
| | d. | | |
| | e. | | |
| | f. | | |
| | g. | | |
| | | | |
| 2 | Generation ផលិតកម្ម | kWh | |
| | Energy Generated បរិមាណថាមពលផលិត | | |
| | a. | | |
| | b. | | |

# តារាងឧបសម្ព័ន្ធទី២

## តារាងលក់ថាមពល

## Table for Total Sale

ឈ្មោះអ្នកកាន់អាជ្ញាបណ្ណ៖

Name of the Licensee:

លេខអាជ្ញាបណ្ណ៖

License Number

ទិន្នន័យសម្រាប់ខែ៖

Data for the month of:

| Type of Sale<br>ប្រភេទនៃការលក់ | | No. of Consumers<br>ចំនួនអតិថិជន | kWh sold<br>ចំនួនថាមពលលក់ | Tariff of Sale<br>អត្រាថ្លៃលក់ |
|---|---|---|---|---|
| | | | | |
| 1. Sale to Other licensees លក់បន្តឲ្យអ្នកកាន់អាជ្ញាបណ្ណ | | | | |
| | a. Sale at MV with metering in MV<br>លក់លើ MV នាឡិកាស្ទង់ MV | | | |
| | b. Sale at MV with metering on LV of Transformer<br>លក់លើ MV នាឡិកាស្ទង់ LV ក្រោមនៃត្រង់ស្វូ | | | |
| | c. Sale at LV លក់លើ LV | | | |
| | | | | |
| 2. Sale to Consumers at MV លក់ឲ្យអតិថិជន MV (ឧស្សាហកម្ម ពាណិជ្ជកម្ម) | | | | |
| | a. Sale at MV with metering in MV<br>លក់លើ MV នាឡិកាស្ទង់ MV | | | |
| | b. Sale at MV with metering on LV of Transformer<br>លក់លើ MV នាឡិកាស្ទង់ LV ក្រោមនៃត្រង់ស្វូ | | | |
| | | | | |
| 3. Sale to consumers at LV លក់លើតង់ស្យុងទាប (អតិថិជនទូទៅ) | | | | |
| | | | | |

# តារាងឧបសម្ព័ន្ធទី៣

## តារាងគណនាចំនួនប្រាក់ឧបត្ថម្ភ

## Table for calculation of subsidy amount

ឈ្មោះអ្នកកាន់អាជ្ញាបណ្ណ៖

Name of the Licensee:

លេខអាជ្ញាបណ្ណ៖

License Number

ទិន្នន័យសម្រាប់ខែ៖

Data for the month of:

| | Type of Sale<br>ប្រភេទនៃការលក់ | Total sold<br>សរុបចំនួនលក់<br>kWh | Cost based Tariff approved by EAC in<br>អត្រាថ្លៃគោលកំណត់ដោយ<br>អាជ្ញាធរអគ្គិសនីកម្ពុជា<br>Riels/kWh | Subsidizes Tariff of Sale approved by EAC in<br>អត្រាថ្លៃឧបត្ថម្ភកំណត់ដោយ<br>អាជ្ញាធរអគ្គិសនីកម្ពុជា<br>Riels/kWh | Subsidy rate<br>អត្រាថ្លៃឧបត្ថម្ភធន<br>in Riels per kWh | Amount of Subsidy<br>ចំនួនប្រាក់ឧបត្ថម្ភធន<br>in Riels |
|---|---|---|---|---|---|---|
| a | b | c | d | e | f = d - e | g = c x f |
| 1 | Sale to consumers at LV<br>ថាមពលលក់លើតង់ស្យុងទាប | | | | | |

| | Type of Sale<br>ប្រភេទនៃការលក់ | No. of Consumers<br>ចំនួនអតិថិជន | Total sold<br>ចំនួនថាមពលលក់<br>( kWh ) | Additional Subsidy rate in<br>អត្រាជួយឧបត្ថម្ភបន្ថែម<br>Riels per kWh | Amount of additional Subsidy<br>ចំនួនប្រាក់ឧបត្ថម្ភបន្ថែម |
|---|---|---|---|---|---|
| a | b | c | d | e | f = d x e |
| ១ | Sale to residence consumers at LV less than 10 kWh/month<br>លក់ឲ្យលំនៅដ្ឋានប្រើតិចជាង 10 kWh/ខែ | | | = 800 - 480 | |
| ២ | Sale to agriculture consumers at LV from 09:00 pm to 07:00 am<br>លក់ឲ្យការបូមទឹកធ្វើកសិកម្ម<br>ពៅម៉ោង ០៩:០០ យប់ ដល់ម៉ោង ០៧:០០ ព្រឹក | | | = 800 - 480 | |